PTI0074

សម្ភាសជាមួយឈ្មោះ កយ ស៊ូ ភេទ ស្រី អាយុ ៤៨ឆ្នាំ

មុខងារខ្មែរក្រហមៈ នៅក្នុងកងធ្វើឥដ្ឋ និងក្បឿង

មុខងារបច្ចុប្បន្នៈ ធ្វើស្រែ

មានស្រុកកំណើតនៅៈ ភូមិស្គល់ ឃុំក្រឡាច ស្រុកកោះអណ្តែត ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:២៨:៥២

ទំព័រ១២

ប៊ុនថន : ដំបូងខ្ញុំសុំស្គាល់ឈ្មោះអ្នកមីងៗឈ្មោះអី?

ស៊ូ : ខ្ញុំឈ្មោះ កយ ស៊ូ ។

ប៊ុនថន : មីងអាយុប៉ុន្មានហើយមីងសព្វថ្ងៃ?

ស៊ូ : អាយុ៤៨ហើយ ។

ប៊ុនថន : មីងមានស្រុកកំណើតនៅភូមិឃុំអីដែរអ្នកមីង?

ស៊ូ : នៅកាលហ្នឹងគេហៅភូមិស្គល់ ឃុំក្រឡាច ស្រុកកោះអណ្តែត ខេត្តតាកែវ ។

ប៊ុនថន : បាទ!សព្វថ្ងៃមីងនៅភូមិឃុំអីដែរ ភូមិហ្នឹង?

ស៊ូ : នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

ប៊ុនថន : បាទ!មីងកាលពីមីងនៅស្រុកហ្នឹង មីងរៀនបានដល់ថ្នាក់ណាដែរមីង?

ស៊ូ : ខ្ញុំរៀនហ្នឹងរៀនថ្នាក់ទី៣ ទី៤ហ្នឹង មិនបានរៀនអាល័យតែ ។

ប៊ុនថន : ទី៣ ទី៤សង្គមចាស់អ្នកមីង?

ស៊ូ : អត់ទេ!សម័យយើង៣ឆ្នាំហ្នឹង ។

ប៊ុនថន : អ្ហូ!បានរៀនដែរអ្នកមីង?

ស៊ូ : ចា៎!ហើយរត់ម៉ោរហូតអញ្ចឹងម៉ោ គ្មានបានរៀនអីទៀត ។

ប៊ុនថន : អកមីងមានបងប្អូនប៉ុន្មាននាក់មីង?

ស៊ូ : បងប្អូនខ្ញុំ៨នាក់ ។

ប៊ុនថន ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ស៊ូ ៖ ដូចប្រុស៣ ស្រីច្រើនជាង ស្រី៥នាក់ ប្រុស៣នាក់។

ប៊ុនថន ៖ មីងកូនទីប៉ុន្មាន?

ស៊ូ ៖ កូនទី៦ហើយ។

ប៊ុនថន ៖ អញ្ចឹងបងប្អូនមីងនៅរស់ទេមីង?

ស៊ូ ៖ នៅរស់។

ប៊ុនថន ៖ នៅទាំងអស់ទេ?

ស៊ូ ៖ នៅ៥នាក់ បាត់៣។

ប៊ុនថន ៖ បាត់ទៅណាវិញមីង?

ស៊ូ ៖ មិនដឹងទៅណា បែបស្លាប់យើងសម័យ៣ឆ្នាំមិនដឹង បើអត់ស្រាវជ្រាវផង។

ប៊ុនថន ៖ បាទ!គាត់ចូលកងដែលមីង?

ស៊ូ ៖ ចូលកង។

ប៊ុនថន ៖ ហើយអត់ដែលឮដំណឹងគាត់ទេ?

ស៊ូ ៖ អត់ដែលឮដំណឹង ខ្លះថាស្លាប់រត់៧៩ ខ្លះថាទឹមស្លាប់ឥឡូវហ្នឹង។

ប៊ុនថន ៖ បាទ!ចុះមីងឪពុកម្តាយនៅរស់ទេសព្វថ្ងៃ?

ស៊ូ ៖ នៅឪពុក ម្តាយស្លាប់ហើយសព្វថ្ងៃ។

ប៊ុនថន ៖ គាត់ស្លាប់ពីអង្កាល់?

ស៊ូ ៖ ៣-៤ឆ្នាំហើយ ឥឡូវនៅពុក។

ប៊ុនថន ៖ គាត់នៅណាវិញអ្នកមីង?

ស៊ូ ៖ គាត់នៅតាកែវ។

ប៊ុនថន ៖ ចុះបងប្អូនមីង?

ស៊ូ ៖ បងប្អូននៅស្រុកនោះទាំងអស់ នៅនេះតែខ្ញុំ។

ប៊ុនថន ៖ មានដែលទៅលេងទេមីង?

ស៊ូ ៖ ទៅ៣-៤ដង។

ប៊ុនថន ៖ ចុះបងប្អូនមានដែលមកលេងនេះទេ?

ស៊ូ ៖ បងប្អូនម៉ោ ម៉ោកាលការកូនខ្ញុំហ្នឹង អ្នកខ្លះមិនទាន់ទៅវិញផង។

ប៊ុនថន ៖ អ្ហូ!ការអង្កាល់មីង?

ស៊ូ : ការខែ២យើង ដែលខែមុនហ្នឹង ។

ប៊ុនថន : បាទ!ចុះពូស្រុកកំណើតនៅណា?

ស៊ូ : កំពង់ចាម ។

ប៊ុនថន : ជួបគ្នាពេលអន្តាល់មីង?

ស៊ូ : ជួបគ្នាពេលម៉ោព្រំដែនហ្នឹង ព្រំដែនថៃ ។

ប៊ុនថន : បាទ!គាត់កងទ័ពដែរមីង?

ស៊ូ : គាត់កងទ័ពដែលហ្នឹង ។

ប៊ុនថន : ចុះអ្នកមីងកាលពីនៅស្រុកហ្នឹងមីងបានចូលកងអីទេមីង?

ស៊ូ : ចូលកងដែលហ្នឹង ។

ប៊ុនថន : កាលហ្នឹងឆ្នាំណាមីងមានចាំទេ?

ស៊ូ : ឆ្នាំ៧៧-៧៨ហ្នឹង កាលហ្នឹងខ្ញុំនៅតូចដែរ ។

ប៊ុនថន : កាលហ្នឹងអាយុប៉ុន្មានមីង?

ស៊ូ : ១៣-១៤-១៥ឆ្នាំ ។

ប៊ុនថន : កាលដំបូងហ្នឹងគេរើសចូលអ្នកមីង?

ស៊ូ : រើសចូល ប៉ុនខ្ញុំមិនទៅធ្វើអីណា រើសចូលកងនៅធ្វើក្បឿងធ្វើអីហ្នឹង បោះក្បឿងបោះ
អីនៅស្រុកនៅភូមិហ្នឹង ។

ប៊ុនថន : មីងធ្វើខាងក្បឿង?

ស៊ូ : ចា៎!ធ្វើឥដ្ឋធ្វើអីហ្នឹង ។

ប៊ុនថន : អ្ហ៎!ស្រីៗគេយកដែរមីង?

ស៊ូ : គេយក យើងធ្វើអារៀបឥដ្ឋរៀបអីហ្នឹង បោះឥដ្ឋបោះអីអាដីដំបូកយើងហ្នឹងជំនាន់ ហ្នឹង ។

ប៊ុនថន : បាទ!គេធ្វើម៉េចទៅមីង?

ស៊ូ : គេយកដីដំបូក គេជាន់ បោះពុម្ពបោះអីវាជាន់នឹងជើងយើងហ្នឹង ប៉ុនពុម្ពវាក្តារ ។

ប៊ុនថន : ដូចយើងរាល់ថ្ងៃ ឥដ្ឋអីរាល់ថ្ងៃហ្នឹងមីង?

ស៊ូ : អត់ទេ!ឥដ្ឋយើងឥដ្ឋអត់ប្រហោងផង ឥដ្ឋជ្រុង ឥដ្ឋប៉ែតៗនោះអាឥដ្ឋស្តើង មិនមែន
អាឥដ្ឋប្រហោងទេ ។

ប៊ុនថន : បាទ!អញ្ចឹងគេមានដុតអីដែលអ្នកមីង?

ស៊ូ : ហ្នឹងហើយជំនាន់ហ្នឹងដុតដែល នៅភូមិខ្ញុំហ្នឹងគេធ្វើឡប៉ុនណាណើ ។

ប៊ុនថន ៖ បាទ! គេយកធ្វើអីវិញមីងឥដ្ឋហ្នឹង?

ស៊ូ ៖ មិនដឹងយកទៅធ្វើអី កាលហ្នឹង ។

ប៊ុនថន ៖ គេយករៀបផ្ទះ រៀបអីដូចឥឡូវនេះ?

ស៊ូ ៖ ចាំ!

ប៊ុនថន ៖ កាលហ្នឹងខាងណាគេ ដូចថាយើងស្ម័គ្រចិត្តចូលមីងឬមានគេរើសអី?

ស៊ូ ៖ គេជ្រើសរើសអញ្ចឹងទៅ គេជ្រើសរើសឲ្យទៅនៅខាងណាៗទៅ ។

ប៊ុនថន ៖ បាទ! ប្រធានកង ឬមួយប្រធាមភូមិអ្នកជ្រើសរើហ្នឹង?

ស៊ូ ៖ មិនដឹងម៉េចបើអត់មានចាំដែរ នៅតូចៗដែល នៅតូចៗហ្នឹងប្រធានកងប្រធានភូមិហ្នឹង មិនដឹង ។

ប៊ុនថន ៖ ចុះអ៊ុំជ្រើសរើសច្រើនទេមីងចូល?

ស៊ូ ៖ ច្រើនព្រោះកងខ្ញុំហ្នឹងច្រើនដែរ ។

ប៊ុនថន ៖ ប៉ុន្មាននាក់ម៉ាកងហ្នឹង?

ស៊ូ ៖ ហ៊ី! រាប់មិនអស់ច្រើន ជិត៥០-៦០នាក់ដែលម៉ាកន្លែងហ្នឹង ។

ប៊ុនថន ៖ បាទ!

ស៊ូ ៖ នៅតែម៉ាអគ្គភាពហ្នឹង អាហ្នឹងគេហៅអគ្គភាព ឡកឿ្យងគេហ្នឹងគេហៅ ។

ប៊ុនថន ៖ មានអ្នកគ្រប់គ្រងគេដែរកាលហ្នឹង?

ស៊ូ ៖ មាន ។

ប៊ុនថន ៖ កាលហ្នឹងពីណាគេ?

ស៊ូ ៖ ប្រធានកងខ្ញុំមិនដឹងឈ្មោះអីទេនៅភូមិហ្នឹងភ្លេចអស់ហើយខ្ញុំ ។

ប៊ុនថន ៖ បាទ! ចុះអ្នកគែប់គ្រងទូទៅទាំងអស់ គ្រប់គ្រងរួមពីណាគេអ្នកមីង?

ស៊ូ ៖ មិនដឹងពីណាទេ បើមិនសូវស្គាល់ផងប្រធានភូមិ ប្រធានឃុំ នៅតូចៗហើយគេរើស ម៉ោចេះតែម៉ោគេទៅ ។

ប៊ុនថន ៖ ចុះក្រោយពីការងារជាន់ដីធ្វើឥដ្ឋហ្នឹង មីងមានធ្វើអីទៀតនៅនោះ?

ស៊ូ ៖ មានធ្វើអីទៀតដល់ហើយ ដូចថាយួនចូលស្រុកៗអញ្ចឹងទៅ ក៏រត់ទៀតម៉ោ ។

ប៊ុនថន ៖ អ៊ូ! មីងនៅនោះរហូតមីង នៅកន្លែងធ្វើឥដ្ឋនោះរហូតមីង?

ស៊ូ ៖ ចាំ!

ប៊ុនថន ៖ រហូតដល់៧៩?

ស៊ូ ៖ ហ្នឹងហើយ រត់ម៉ោៗរហូតភ្នំហ្នឹងម៉ោ ។

ប៊ុនថន ៖ បាទ!អញ្ចឹងក្រោពីការងាររដាន់ដីធ្វើឥដ្ឋៗ ហ្នឹងម៉ោមីងធ្វើអីទៀតមីង?

ស៊ូ ៖ គ្មានធ្វើអី ។

ប៊ុនថន ៖ ចង់និយាយថាអត់ធ្វើស្រែធ្វើអីទេ?

ស៊ូ ៖ អត់!ចុះកាលហ្នឹងជំនាន់ហ្នឹងគេរើស កុមារៗទៅនៅម្តុំ ។

ប៊ុនថន ៖ បាទ!

ស៊ូ ៖ ចា៎!មិនដែលធ្វើស្រែ មិនដែលបានធ្វើស្រែគេទេ ។

ប៊ុនថន ៖ អញ្ចឹងនៅហ្នឹងគេបែងចែកម៉េចទៅមីង គេបែងចែកការងារខាងអីខ្លះមីង ខាងមីងនៅកន្លែងធ្វើឥដ្ឋហ្នឹង?

ស៊ូ ៖ ដូចមិនសូវដឹងផង ព្រោះនៅតូចៗ ឃើញនៅតែធ្វើឥដ្ឋហ្នឹងម៉ងនៅក្នុងកងហ្នឹង ។

ប៊ុនថន ៖ មីងធ្វើអីខ្លះមីងជំនាន់ហ្នឹង?

ស៊ូ ៖ បោះក្បឿងហើយនឹងដាន់ឥដ្ឋហ្នឹង ចាស់ៗគាត់រៀបឡធំខ្ពស់ហ្នឹង គាត់បញ្ចូលអាឥដ្ឋហ្នឹងដុតទៅ គាត់ដឹងគាត់យកទៅធ្វើអីៗទៀតទៅ ។

ប៊ុនថន ៖ ខាងលើកដាក់?

ស៊ូ ៖ ចា៎!

ប៊ុនថន ៖ អញ្ចឹងគេបែកចែកការរស់នៅអី ឲ្យនៅជាមួយគ្នាអ្នកមីង?

ស៊ូ ៖ ទេ ខាងខ្ញុំនោះអត់មានប្រុសផង មានសុទ្ធតែស្រីៗកុមារីទាំងអស់ អត់មានកុមារប្រុសៗនៅផង ។

ប៊ុនថន ៖ អញ្ចឹងស្រីៗធ្វើការលើសអីអញ្ចឹងធ្ងន់ៗ?

ស៊ូ ៖ អត់ធ្ងន់ផង កាន់ដីមួយដុំៗម្នាក់ៗតគ្នារហូតហ្នឹងគ្មានធ្វើអី ។

ប៊ុនថន ៖ អ្ហូ!គ្រាន់តែហុចទេ?

ស៊ូ ៖ ចា៎!នេះហុចម៉ោមួយដុំអញ្ចឹងទៅឲ្យអានោះទៅ មានពិបាកអី ។

ប៊ុនថន ៖ អ្ហូ!អត់ហត់ទេ?

ស៊ូ ៖ ចា៎!អត់ហត់ផង កាលជំនាន់ខ្ញុំធ្វើអាហ្នឹងអត់មានហត់ផង ។

ប៊ុនថន ៖ ហើយអញ្ចឹងរស់នៅតែស្រីៗទេ?

ស៊ូ ៖ អត់ដែលរស់នៅឃើញគេកាប់សម្លាប់អីផង ជំនាន់ហ្នឹងខ្ញុំ ។

ប៊ុនថន ៖ បាទ!អ្នកមីងដូចថារបបហូបចុកអីយ៉ាងម៉េចដែលកាលជំនាន់នោះ?

ស៊ូ : កាលជំនាន់ហ្នឹងខ្ញុំហូបចុកធម្មតា បើថាម្ដុំផ្ទះម៉ែ ផ្ទះប្អូនអីហ្នឹងហូបបបរហូបអីហ្នឹង ខ្ញុំមានអង្គភាពអញ្ចឹងដូចមានគេជួយ មេភូមិមេឃុំគេអករើសជួយអញ្ចឹងទៅ គេឧបត្ថម្ភ ថាមានកូននៅកន្លែងហ្នឹងអញ្ចឹង គេរ៉ៃគ្នាយកម៉ោហូបបបរដែលហ្នឹងកាលហ្នឹង ។

ប៊ុនថន : បាទ!ប៉ុនយើងគ្រាន់បើជាងកន្លែងផ្សេង?

ស៊ូ : ចា៎!គ្រាន់បើ តែនៅរាងពិបាកផងអត់សូវដឹង ដាក់មានគេដាក់ទោសឲ្យទៅកាប់ដីដឹបូក កាប់ដីអី ហើយខ្ញុំអត់ដែលជួបផង ។

ប៊ុនថន : អ៊ូ!នៅកងមីងមានទេ ដូចថាអ្នកដែលធ្វើខុសអីអញ្ចឹង?

ស៊ូ : បែបធ្វើខុសអីហើយ បានគេឲ្យកាប់ដីដឹបូកកាប់អី ។

ប៊ុនថន : អញ្ចឹងកាលអ្នកមីងនៅហ្នឹង ដូចថាកុមារក្នុងកងធ្វើខុសអីមានពិន័យទេអ្នកមីង?

ស៊ូ : កុមារកងខ្ញុំហ្នឹងដូចអត់មានខុសអីផង អត់មានលំបាកអីផង អត់ដែលមានលំបាកអីផង នៅធ្វើតែឥដ្ឋហ្នឹង ។

ប៊ុនថន : បាទ!ទៅដល់ហ្នឹង ដល់៧៩បានមីងរត់ទៅ?

ស៊ូ : ចា៎!

ប៊ុនថន : មីងដឹបូងរត់ទៅណាវិញមីង?

ស៊ូ : ខ្ញុំដឹបូងគេរើសទៅភ្នំពេញដែលហ្នឹង ។

ប៊ុនថន : អ៊ូ!ភ្នំពេញដែរ?

ស៊ូ : ចា៎!

ប៊ុនថន : ឆ្នាំប៉ុន្មានម៉ោភ្នំពេញអ្នកមីង?

ស៊ូ : អត់ចាំទេឆ្នាំ៧៧ហ្នឹងមិនដឹង ៧៧ហ្នឹងហើយខ្ញុំម៉ោនៅ ដល់៧៩ខ្ញុំរត់ម៉ោនៅភ្នំហ្នឹង រហូតកាលហ្នឹង ។

ប៊ុនថន : កាលហ្នឹងគេជ្រើសរើសម៉ោប៉ុន្មាននាក់អ្នកមីងម៉ោពីកងហ្នឹង?

ស៊ូ : ម៉ោច្រើនកាលហ្នឹង ម៉ាអង្គភាពខ្ញុំហ្នឹងជិត៣០នាក់ម៉ោភ្នំពេញហ្នឹង ។

ប៊ុនថន : យក៣០នាក់ម៉ោអ្នកមីង?

ស៊ូ : ចា៎!ប៉ុនអត់ចាំគ្នាទេ ខ្លះយកទៅនេះ ខ្លះយកទៅនោះ ។

ប៊ុនថន : ខាងពីអង្គភាពអ្នកជ្រើសរើស ឬក៏អង្គភាពគេនៅភ្នំពេញគេអ្នកជ្រើសរើស?

ស៊ូ : មិនដឹងពីណាទេ ឮគេឲ្យម៉ោៗ ម៉ោនៅតាកែវហ្នឹងបាន៣-៤ថ្ងៃឃើញគេដឹកម៉ោទៀត ម៉ោ ម៉ោអញ្ចឹងរហូតម៉ោ នៅភ្នំពេញបានប៉ុន្មាន ។

ប៊ុនថន : នៅខាងអីនៅភ្នំពេញ?

ស៊ូ : នៅធ្វើពេទ្យ។

ប៊ុនថន : ខាងពេទ្យ?

ស៊ូ : ចា៎!

ប៊ុនថន : ពេទ្យណាវិញមីង?

ស៊ូ : ពេទ្យ គេហៅពេទ្យ១៧ហ្នឹង។

ប៊ុនថន : ពេទ្យ១៧ ពេទ្យរុស្សីហ្នឹងអ្នកមីង?

ស៊ូ : ចា៎!

ប៊ុនថន : នៅ និយាយថាម៉ោហ្នឹងគេបង្ហាត់បង្រៀនឬក៏ម៉ោ?

ស៊ូ : គេបង្ហាត់បង្រៀនចាក់ថ្នាំ ចាក់អីហ្នឹង កាលជំនាន់ហ្នឹងគេសុទ្ធតែពេទ្យចិន ពេទ្យអី នោះ។

ប៊ុនថន : មានពេទ្យចិនដែរ?

ស៊ូ : ចា៎!ពេទ្យចិន គេឲ្យរៀនបកប្រែបកអីដែរ ប៉ុននៅក្មេងពេកអត់ចេះអីផង នៅដើរតែលេងហ្នឹង។

ប៊ុនថន : បកប្រែកអីកាលហ្នឹង?

ស៊ូ : បកប្រែចិនដែលហ្នឹង ឲ្យរៀនភាសាអីអត់ចេះអីផង គិតដើរតែលេង។

ប៊ុនថន : ហើយម៉ោអញ្ចឹងគេបង្រៀនដែលអ្នកមីង គេបង្រៀន?

ស៊ូ : សិស្សសាលាហ្នឹងគេបង្រៀនរាល់ថ្ងៃដែលហ្នឹង ដល់ពេលម៉ោវិញបានធ្វើការលាងរបួស ចាក់ថ្នាំអីអញ្ចឹងទៅ។

ប៊ុនថន : មួយថ្ងៃប៉ុន្មានម៉ោរៀន?

ស៊ូ : មិនដឹងប៉ុន្មានម៉ោទេ ទៅដើរលេងខ្លះអីខ្លះ រៀនខ្លះ។

ប៊ុនថន : រៀននៅណាមីង រៀននៅក្នុងពេទ្យហ្នឹងម៉ង ឬរៀននៅក្រៅ?

ស៊ូ : ចា៎!រៀននៅសាលានៅពេទ្យហ្នឹង។

ប៊ុនថន : ច្រើននាក់ដែលអ្នកមីងរៀន កូនសិស្ស?

ស៊ូ : ច្រើនដែរ ក្មេងៗ តែខ្ញុំទេគ្រប់ខេត្ត គ្រប់ស្រុកទៅ។

ប៊ុនថន : គ្រូបង្រៀនខ្មែរទេមីង?

ស៊ូ : ខ្មែរ។

ប៊ុនថន : គេបង្រៀនអីខ្លះទៅមីង មាននៅចាំទេកាលហ្នឹង?

ស៊ូ ៖ បង្រៀនអី បង្រៀនតែអក្សរសាស្ត្រយើងហ្នឹង រៀនតាំងពីខ្ញុំនៅតូចៗដែរ រៀនតាំងពីស្រះអ ស្រះអា ឡើងទៅ។

ប៊ុនថន ៖ អ្ហូ!បង្រៀនអក្សរឬក៏បង្រៀនចាក់ថ្នាំអីអ្នកមីង?

ស៊ូ ៖ បង្រៀនចាក់ថ្នាំ បង្រៀនចាក់ផ្សេង មិនដែលអីរៀនឲ្យចាក់ខ្ទើយចាក់អីអញ្ចឹងទៅ មានចាក់ខ្ទើយអី ចាក់មនុស្សម៉ង។

ប៊ុនថន ៖ អញ្ចឹងមីងដូចថាចង់រៀនទេ ផ្នែកពេទ្យកាលហ្នឹង?

ស៊ូ ៖ គេឲ្យទៅហើយចេះចង់ បើគេសុទ្ធតែរើស រើសតាមហ្នឹងទៅ។

ប៊ុនថន ៖ គេរើសម៉េចទៅ ដូចក្មេងហ្នឹងឆ្លាត?

ស៊ូ ៖ ចា៎!ដូចថាទៅពីខេត្តអញ្ចឹងទៅ ប្រមាណជា១០នាក់ ២០នាក់អញ្ចឹងទៅ គេទៅខាងស្ល ថ្នាំអញ្ចឹងទៅ ខ្លះទៅធ្វើពេទ្យអញ្ចឹងទៅ ខ្លះទៅរោងចក្រអញ្ចឹងទៅ គេនាំគ្នាទៅ។

ប៊ុនថន ៖ បាទ!

ស៊ូ ៖ គ្មានបានធ្វើប៉ុន្មានទេ គ្រាន់តែ៧៩ទៅក៏រត់ម៉ោរហូតទៅ។

ប៊ុនថន ៖ ចុះនៅនោះមីងធ្វើការអីខ្លះ នៅពេទ្យនោះការងារ?

ស៊ូ ៖ អត់មានធ្វើអីទេខ្ញុំនៅក្មេងៗដែរ អត់ឲ្យធ្វើអីផង។

ប៊ុនថន ៖ និយាយខាងផ្នែកដូចមីងនិយាយម៉េញ ខាងផ្នែកចាក់ថ្នាំ?

ស៊ូ ៖ ចាក់ថ្នាំ លាងរបួស អ្នកជំងឺហ្នឹងប៉ុនហ្នឹង។

ប៊ុនថន ៖ មីងចេះមើលថ្នាំដែរ?

ស៊ូ ៖ ចេះមើលខ្លះដែលមិនអត់ទេ ចេះតិចៗហ្នឹង។

ប៊ុនថន ៖ ភាសាខ្មែរឬក៏ភាសាបរទេះកាលហ្នឹង និយាយថាថ្នាំមីង?

ស៊ូ ៖ ថ្នាំៗមើលខ្មែរយើងទៅ មានថ្នាំខ្លះបរទេះ ប៉ុនយើងចេះចាំខ្លះទៅ។

ប៊ុនថន ៖ ចំណាំអញ្ចឹង?

ស៊ូ ៖ ចា៎!នៅក្មេងៗមិនទាន់ចេះអី។

ប៊ុនថន ៖ ចុះកាលគេឲ្យមីងទៅរៀនបកប្រែចិននោះ?

ស៊ូ ៖ គេឲ្យទៅរៀនយើងចូលទៅរៀនមិនយើងមិនទៅ មិនចេះ នៅក្មេងពេកជំនាន់ហ្នឹងនៅតូចៗ។

ប៊ុនថន ៖ រៀនហ្នឹងរៀនភាសា ឬក៏រៀនខាងពេទ្យម៉ង?

ស៊ូ ៖ រៀនពេទ្យ រៀនភាសាបកប្រែហ្នឹង ចិនគេម៉ោនៅប្រចាំនៅហ្នឹងដែរ។

ប៊ុនថន :   បាទៗ !មានចិនច្រើនទេអ្នកមីង?

ស៊ូ :   ចិនច្រើន មានស្រីមានប្រុសម៉ោ ។

ប៊ុនថន :   ប៉ុនចិនហ្នឹងដូចថាមេ អ្នកគ្រប់គ្រងដូចថាផ្នែកៗ ឬក៏យ៉ាងម៉េចដែរ?

ស៊ូ :   មិនដឹងម៉េចដែរ មិនដឹងខាងអីៗទេ ខ្ញុំមិនសូវដឹងដែល ឃើញតែដើរទាំងវ៉ុងៗ ។

ប៊ុនថន :   សុទ្ធតែចិន?

ស៊ូ :   ចា៎!

ប៊ុនថន :   បាទ!ចុះខ្មែរមានទេអ្នកមីង?

ស៊ូ :   ខ្មែរជាមួយចិនហ្នឹងអ្នកបកប្រែ ។

ប៊ុនថន :   ចុះមានចេះចិត្តអីខ្លះៗទេ ពេលហូបបាយអីមីង?

ស៊ូ :   អត់ចេះទេ បើគ្មានចេះអីផងកាលហ្នឹងនៅតូចៗដែរ ដឹងតែដើរលេងហ្នឹងខ្ញុំ ដឹងតែដើរលេងគ្មានខំរៀនទេជំនាន់ហ្នឹង គ្រាន់តែរៀនៗ៧៩ លើភ្នំហ្នឹងម៉ងបានខំរៀនចេះមើលចេះអក្សរអីហ្នឹងម៉ោរៀនលើភ្នំហ្នឹងម៉ង រៀនៗសង្គ្រាមគ្រាប់ផ្លោងគ្រាប់អីហ្នឹងម៉ង ។

ប៊ុនថន :   មានអ្នកជំងឺអីច្រើនទេអ្នកមីងនៅនោះ ?

ស៊ូ :   កាលហ្នឹងមានច្រើន ។

ប៊ុនថន :   អ្នកជំងឺភាគច្រើនឈឺអីវិញអ្នកមីង?

ស៊ូ :   របួស តាមផ្នែកវាហ្នឹងអ្នករបួសដាក់របួសទៅ ទូទៅដាក់ទូទៅអញ្ចឹង ។

ប៊ុនថន :   បាទ!អ្នកជំងឺម៉ោពីខាងណាអ្នកមីង?

ស៊ូ :   មិនដឹងម៉ោពីខាងណាខាងណី បើខ្ញុំមិនសូវស្គាល់ខេត្តស្គាល់ក្រុងអីផងកាលហ្នឹង ជំនាន់ហ្នឹងនៅតូចៗមិនសូវស្គាល់ទេ ។

ប៊ុនថន :   បាទ!អញ្ចឹងមានខាងទាហានមានអីទេ មីង?

ស៊ូ :   មាននៅពេទ្យហ្នឹង ។

ប៊ុនថន :   ចុះអ្នកគ្រប់គ្រងនៅពេទ្យហ្នឹងពីណាមីង?

ស៊ូ :   ជំនាន់ហ្នឹងឈ្មោះពូ ពឿន អញ្ចឹងអី ។

ប៊ុនថន :   អី ពឿន?

ស៊ូ :   អត់ស្គាល់ផង គាត់ស្លាប់បាត់ហើយ តា ជុំ ជឿន អីហ្នឹង ។

ប៊ុនថន :   អ្ហូ!ជុំ ជឿន?

ស៊ូ :   ចា៎!គាត់មេdoctor ធំនៅហ្នឹង ។

ប៊ុនថន ៖ បាទ!គាត់កាន់ខាងពេទ្យហ្នឹង?

ស៊ូ ៖ ពេទ្យហ្នឹង ។

ប៊ុនថន ៖ ចុះកាលហ្នឹងអ្នកមីងដែលជួបគាត់ទេ?

ស៊ូ ៖ អត់ដែលជួបទេ មិនដឹងគាត់ចំណាស់ប៉ុន្មានទេ ។

ប៊ុនថន ៖ គាត់ខស្សវាហ៍ចុះមើលទេអ្នកមីង?

ស៊ូ ៖ ជំនាន់ហ្នឹង?

ប៊ុនថន ៖ បាទ!

ស៊ូ ៖ ធ្លាប់ឃើញគាត់ដើររាល់ថ្ងៃដែលហ្នឹង ។

ប៊ុនថន ៖ ចុះនៅខាងហ្នឹងមីងដែលប្រជុំដែលអីទេពេទ្យ ដូចថាមានប្រជុំមានអីអញ្ចឹង?

ស៊ូ ៖ ជំនាន់ហ្នឹង គេប្រជុំអ្នកបងៗធំ ខ្ញុំក្មេងៗមិនសូវដែលហៅប្រជុំទេ នៅតែដើរលេងទេ គ្មានសូវដឹងអីផងកាលហ្នឹង ។

ប៊ុនថន ៖ បាទ!ចុះដែលមានភ្ញៀវអីទៅមើលទេអ្នកមីង ដូចថាភ្ញៀវគេទៅទស្សនៈកិច្ចពេទ្យនៅអី អញ្ចឹង ដែលមានទេ?

ស៊ូ ៖ មានមិនអត់ទេ ភ្ញៀវចិន ។

ប៊ុនថន ៖ បាទ!មានចិន ជាតិសាសន៍ផ្សេងៗទៀតមានទេមីង?

ស៊ូ ៖ អត់ទេ!មិនដែលផង មិនសូវដែលដើរផង កាលជំនាន់ហ្នឹងនៅតូចៗ មិនសូវដើរទេ យប់ប្រលប់អីអត់ហានដើរទេ ។

ប៊ុនថន ៖ បាទ!អ្នកមីងនៅហ្នឹងបានប៉ុន្មានឆ្នាំអ្នកមីង?

ស៊ូ ៖ អត់ចាំ មិនដឹងបានប៉ុន្មានឆ្នាំ ។

ប៊ុនថន ៖ ទៅពី៧៧ ទៅពី?

ស៊ូ ៖ ៧៨-៧៩ហ្នឹងរត់ដែរ នៅបានតែបន្តិចហ្នឹង ។

ប៊ុនថន ៖ ដំបូងមីងរត់ទៅណាវិញមីង?

ស៊ូ ៖ រត់ម៉ោសំឡូតម៉ោអីហ្នឹង ធ្លាក់ទៅដល់ដីថ្ងៃដីអី ។

ប៊ុនថន ៖ រត់ម៉ោទាំងអស់គ្នាមីងមាអន្តភាពពេទ្យហ្នឹង?

ស៊ូ ៖ រត់ម៉ោទាំងអស់គ្នាហ្នឹង ប៉ុនម៉ោដល់បាត់ដំបង មិនដឹងអ្នកណារត់ទៅណាទៅណីខ្លះ ។

ប៊ុនថន ៖ អ្ហូ!បាទអញ្ចឹងអ្នកជំងឺនៅក្នុងហ្នឹង?

ស៊ូ ៖ អ្នកជំងឺចេះតែដើររត់ទៅជាមួយគ្នាហ្នឹងទៅ បែកគ្នាអស់មិនដឹងទៅណាទៅណីអស់ ។

ប៊ុនថន ៖ បាទ!អញ្ចឹងអ្នកឈឺធ្ងន់ៗអីនៅ?

ស៊ូ ៖ ចាំ!នៅពេទ្យហ្នឹងទៅ នៅពេទ្យបាត់ដំបងគេដាក់នៅក្នុងអគ្គភាពគេហ្នឹង ។

ប៊ុនថន ៖ អញ្ចឹងពេលរត់ហ្នឹងអ្នកជំងឺគេបញ្ជូនចេញម៉ោដែរ ឬក៏?

ស៊ូ ៖ ចេញម៉ោទាំងអស់ហ្នឹង ។

ប៊ុនថន ៖ អ្នកជំងឺដាក់អីទៅអ្នកមីង បញ្ជូនដាក់អីទៅ?

ស៊ូ ៖ ដាក់រទេះភ្លើងៗម៉ោបាត់ដំបងម៉ោ ខ្ញុំបែកត្រឹមហ្នឹងទៅខ្ញុំរត់ម៉ោចេះវិញទៅ ហើយ មនុស្សនៅ (៣១-៣២) បាត់ដំបងនោះ ។

ប៊ុនថន ៖ ចុះមីងកាលពីរត់ចេញម៉ោជិះរទេះភ្លើងដែរឬក៏ដើរ?

ស៊ូ ៖ ខ្ញុំជិះរទេះភ្លើងដែរ ដើរអត់ដល់ទេ ។

ប៊ុនថន ៖ អញ្ចឹងមីងចេញហ្នឹងមុនវៀតណាមចូលអ្នកមីង ឬក៏វៀតណាមចូលម៉ោបានមីងចេញម៉ោ?

ស៊ូ ៖ មិនដឹងចូលឬនៅទេ គេឲ្យចេញចេះតែចេញទៅ មិនដឹងចូលមិនដឹងនៅបើឲ្យម៉ោ ។

ប៊ុនថន ៖ បាទ!អញ្ចឹងអ្នកមីងទៅដល់បាត់ដំបងម៉ាអគ្គភាពមីងហ្នឹងទៅ?

ស៊ូ ៖ បែកគ្នាអស់ហើយ មិនដឹងអ្នកណាទៅណាទៅណីបែកគ្នាអស់ហើយ ដល់ពេលដើរដើង ទទេអញ្ចឹងបែកគ្នាអស់ហើយ កាលពីភ្នំពេញម៉ោ ម៉ោមូលគ្នា ។

ប៊ុនថន ៖ ជុំគ្នា?

ស៊ូ ៖ ចាំ!ហើយបែកគ្នាអស់ហើយ ។

ប៊ុនថន ៖ បាទ!ហើយអ្នកមីងទៅ មានកងដឹកនាំទេមីង កាលពីទៅសំឡូតហ្នឹង?

ស៊ូ ៖ គ្មានអ្នកណាដឹកនាំទេ ចេះតែទៅៗ ។

អ្នកជិតខាង ៖ កាលហ្នឹងមានហើយ មិនអត់ទេ ប៉ុនគ្រាន់តែមិនដែលឃើញទាហានពេទ្យ អាហ្នឹងវាទៅជារត់តាមអ្នកជំងឺវិញទៅ ។

ប៊ុនថន ៖ អញ្ចឹងអ្នកមីងចេញពីបាត់ដំបងហ្នឹងទៅនៅសំឡូតម៉ង?

ស៊ូ ៖ ចាំ!រត់ម៉ោអញ្ចឹងម៉ោទៅនៅសំឡូតម៉ោ ធ្លាក់ទៅដីថៃជីអី ។

ប៊ុនថន ៖ អញ្ចឹងអ្នកមីងៗទៅនោះមានរៀនអក្ខរកម្ម ទៅហ្នឹងគេរៀនឡើងវិញអ្នកមីង?

ស៊ូ ៖ ហ្នឹងហើយ រៀបចមរៀនហ្នឹងបានចេះបានដឹងហ្នឹង កាលនៅភ្នំពេញមានចេះអី នៅតូចៗដូចមិនសូវរៀនទេ ដើរតែលេង ។

ប៊ុនថន ៖ កាលហ្នឹងនៅណា គេរៀបចំឲ្យមីងរៀនហ្នឹងនៅណា?

ស៊ូ ៖ នៅ (០១-០២) ក្បែរព្រំដែនថៃហ្នឹង ។

ប៊ុនថន ៖ នៅដីខ្មែរទេ?

ស៊ូ ៖ ដីខ្មែរ ។

ប៊ុនថន ៖ ហ្នឹងនៅស្រុកអីវិញមីង?

ស៊ូ ៖ នៅសំឡូតហ្នឹង ។

ប៊ុនថន ៖ ហើយមីងនៅក្នុងអង្គភាពពេទ្យដដែល?

ស៊ូ ៖ ចា៎! នៅអង្គភាពដដែលនៅជួបជុំគ្នា នៅកន្លែងហ្នឹង ។

ប៊ុនថន ៖ កាលហ្នឹងមេចាស់ដដែលមីង?

ស៊ូ ៖ មេចាស់ដដែល ។

ប៊ុនថន ៖ ក៏ដូរថ្មី?

ស៊ូ ៖ មេចាស់ដដែល ឈ្មោះ ពូ ពឿន ។

អ្នកជិតខាង ៖ មេចាស់ដដែលមីងនេះហ្នឹង មីង អៀង ធីរិទ្ធិហ្នឹងតើស៎គាត់រៀបចំឡើងវិញ ។

ប៊ុនថន ៖ បាទ! អ៊ូអៀង ធីរិទ្ធិ ប្រពន្ធរបស់ អៀង សារី?

ស៊ូ ៖ ហ្នឹងហើយ យាយតាគាត់ ។

ប៊ុនថន ៖ បាទៗ! អញ្ចឹងអ្នកមីងនៅហ្នឹងគេរើសបញ្ចូលធ្វើពេទ្យវិញទៅ?

ស៊ូ ៖ ចា៎!

ប៊ុនថន ៖ មានបង្រៀនអក្សរមីង?

ស៊ូ ៖ ចា៎!

ប៊ុនថន ៖ មីងនៅសំឡូតហ្នឹងរយៈពេលប៉ុន្មានឆ្នាំ?

ស៊ូ ៖ មិនដឹងប៉ុន្មានទេ អត់ចាំទេ ។

ប្ដី ៖ នៅ១០ឆ្នាំមិនដឹង នៅ៧៨ ដល់៩៣ចូលជិត២០ឆ្នាំហើយ ដល់៩៣បានយើងម៉ោ នេះ ។

ប៊ុនថន ៖ ដល់៩៣មីងឈប់នៅអង្គភាពពេទ្យហើយ?

ស៊ូ ៖ ចា៎! ការហើយហ្នឹង ម៉ោបែករហូត ។

ប៊ុនថន ៖ ៩៣មីងទៅណាវិញមីងដឹងទៅណាទេ?

ប្ដី ៖ ៩៣ម៉ោនៅក្បែរយើងព្រំដែនហ្នឹង ។

ប៊ុនថន ៖ បាទ! នៅសំឡូតដដែលទេ?

ប្ដី ៖ នៅសំឡូតដដែលតែគ្រាន់តែនៅម្ដុំស្ពានយោលតាគោកហ្នឹង ។

ប៊ុនថន : បាទ!ចុះមីងម៉ោងដល់៩៣ហើយមីងម៉ោនៅខាងសំឡូត?

ស៊ូ : ៩៣ ។ ៩៨បានខ្ញុំម៉ោនេះ ។

ប៊ុនថន : អញ្ចឹង៩៨មីងម៉ោងដល់នេះហើយ?

ស៊ូ : ចា៎!

ប៊ុនថន : អញ្ចឹងអ្នកមីងមានអីចង់បន្ថែមទៀតទេអ្នកមីង?

ស៊ូ : អត់មានអីទៀតទេ ។

ប៊ុនថន : បាទៗ!អញ្ចឹងខ្ញុំអរគុណអ្នកមីងច្រើនអ្នកមីងណាស់ ។

ស៊ូ : ចា៎!

**ចប់**